ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រម

តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង០៨ និង០០នាទី នៅសាលសវនាការទី៣ ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ជាប្រធានក្រុមប្រឹក្សា

-លោក [redacted] ជាចៅក្រមប្រឹក្សា

-លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៥៨០ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

ឈ្មោះ [redacted] **សៀនថាន់ ហៅ អាមាន់** ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិខ្មែរ មុខរបរ លក់ឡេ ទីកន្លែងកំណើត [redacted] ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅបន្ទប់F ជាន់ទី៦ ខុនអូរ ផ្លូវបេតុង ភូមិចំរើនផល សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ច្រឹ "រ" ម្តាយឈ្មោះ [redacted] សុខខេង "រ" នៅលីវ ទោសពីមុនគ្មាន ជានីតិជន ។

-តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៥៩៥៧ (ព).ដ.ឃ.ដ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ នៅមណ្ឌលអប់រំកែប្រែទី១ (ម១) ។

-ជាប់ចោទពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចក្បែរវិទ្យាល័យជាស៊ីម បឹងកេងកង សង្កាត់បឹងកេងកង ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ ចំណុច១១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២០
-សំណុំរឿងព្រហ្មទណ្ឌលេខ ៣៥៨០
ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០
-សំណុំរឿងស៊ើបសួរលេខ ២៤២០
ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០
-សំណុំរឿងជំនុំជម្រះលេខ ៥២១៧
ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ
-លេខ ៥៥៣ (ជ.ក្រ.ឲ)

អំពីអង្គហេតុ

តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌,ដីកាសន្និដ្ឋានស្តាពររបស់តំណាងអយ្យការអមសាលាដំបូង រាជធានីភ្នំពេញ និងដីកាដំណោះស្រាយបញ្ហានសំណុំរឿងទៅជំនុំជម្រះ បានលើកឡើងនៅអង្គហេតុនៃរឿងក្តីនេះថា៖

កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង២២ និង៣០នាទីនៅចំណុចក្បែរវិទ្យាល័យជាស៊ីមបឹងកេងកង សង្កាត់បឹងកេងកង ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កម្លាំងការិយាល័យប្រឆាំងបទល្មើសគ្រឿងញៀនឆ្លងដែនរបស់មន្ទីរប្រឆាំងគ្រឿងញៀន នៃក្រសួងមហាផ្ទៃ បានចុះបង្ក្រាបករណី ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយឃាត់ខ្លួនបានជនជាប់ចោទ ឈ្មោះ [redacted] សៀងងាន់ ហៅ អាមាន់ ភេទប្រុស អាយុ ២៩ឆ្នាំ រួមទាំងវត្ថុជាថ្នាំគ្រាប់ពណ៌ចំរុះទម្ងន់ ៦៧,១៧ក្រាម ប្រភេទ (MDMA) ក្រាមពណ៌សផ្កាទម្ងន់ ៥៦,៧៣ក្រាម ប្រភេទកេតាមីន ថ្នាំគ្រាប់ឆីតាហ្សេប៉ាម ទម្ងន់ ១,២៦ក្រាម និងរថយន្តមួយគ្រឿងម៉ាក តូយ៉ូតាព្រូស ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 2AP-5932 បន្ទាប់មកសមត្ថកិច្ចបានបញ្ជូនជន ជាប់ចោទរួមទាំងវត្ថុតាងមកមន្ទីរប្រឆាំងគ្រឿងញៀន ដើម្បីចាត់ការតាមនីតិវិធី ។

-បានឃើញ របាយការណ៍លេខ ៦៤៤ រ.ប.ក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ របស់មន្ទីរប្រឆាំងគ្រឿងញៀន នៃក្រសួងមហាផ្ទៃ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៥៦០ អ.ឃ.ឃ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្តាពរលេខ ៤៦៩៤ អ.ឃ.ឃ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ របស់អយ្យការ អម សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៦១៣៩ (ព).ដ.ដ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

ឆាពេលសវនាការ

១/. ជនជាប់ចោទឈ្មោះ [redacted] សៀងងាន់ បានឆ្លើយថា៖ កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០ ខ្លួនពិតជាបានយក ថ្នាំញៀនចំនួន០១កញ្ចប់ធំ (ប្រភេទ K និងប្រភេទ LV មិនដឹងពីចំនួន) ដែលឈ្មោះ ផល ប្រាប់ថាអោយខ្លួនយកទៅអោយ ឈ្មោះ វុធ ហៅ ឌីជេវុធ នៅម្តុំវិទ្យាល័យជាស៊ីមបឹងកេងកង ពេលទៅដល់ក្រោយវិទ្យាល័យខ្លួនបានទូរស័ព្ទរកឈ្មោះ វុធ អោយមកយកថ្នាំញៀន ពេលឈ្មោះ វុធ មកដល់ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

២/. តាមអំណានលទ្ធផលកោសល្យវិច្ច័យគ្រឿងញៀនលេខ ២៦១៣០/២០ ម.ព.អ.ជ.ប.ត.ញ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋានមន្ទីរពិសោធន៍គ្រឿងញៀន ជាលទ្ធផលបញ្ជាក់ថា៖

ក/សំណាកទី១៖ ជាគ្រឿងញៀនប្រភេទគ្រាប់ ឈ្មោះ [redacted] ដេ អឹម អា (ហៅក្រៅ អ៊ិចស្តាស៊ី) ,ដែលមានកម្រិតភាព សុទ្ធ ៥៦,៥0% នៃទម្ងន់សរុប វាស្ថិតក្នុងតារាងទី១ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

ខ/សំណាកទី២៖ ជាគ្រឿងញៀនប្រភេទក្រាមម្សៅ ឈ្មោះ កេតាមីន ,ដែលមានកម្រិតភាពសុទ្ធ ៦២,0៣% នៃទម្ងន់ សរុប ។

គ/សំណាកទី៣៖ ជាគ្រឿងញៀនប្រភេទគ្រាប់ ឈ្មោះ ន៊ីមេតាហ្សេប៉ាម ,ដែលមានកម្រិតភាពសុទ្ធ ៣% នៃទម្ងន់សរុប វាស្ថិតក្នុងតារាងទី៣ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់ការសាកសួរដេញដោលនាពេលសវនាការរួចមកជនជាប់ចោទបានទទួលស្គាល់នូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ។ ដូច្នេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្តាពរលេខ ៤៦៩៤ អ.ឃ.ឃ ចុះថ្ងៃទី0១ ខែកញ្ញា ឆ្នាំ២0២0 ទុកជាបានការដដែល និងប្តឹងសុំឲ្យតុលាការសម្រេចទៅតាមច្បាប់ ។

សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-លោក [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីសាកសួរដេញដោលនាពេលសវនាការរួចមកគឺ ឈ្មោះ ផល បានទូរស័ព្ទហៅកូនក្តីខ្លួនទៅផ្ទះគាត់ និងបានអោយកូនក្តីខ្លួនយកថ្នាំញៀនទៅអោយឈ្មោះ វុធ នៅវិទ្យាល័យ ជាស៊ីមបឹងកេងកង ពេលទៅដល់ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនរួមទាំងវត្ថុតាងតែម្តង ។ ដូច្នេះស្នើសុំលោកចៅក្រមបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនដោយក្តីអនុគ្រោះ ។

សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] សៀងងាន់ បាននិយាយសំដីចុងក្រោយបង្អស់ថា៖ ស្នើសុំតុលាការបន្ធូរបន្ថយទោសដល់ពួកខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានលទ្ធផលកោសវិច្ឆ័យ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សំអាងហេតុ

១/. ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៦១៣៩ (ព).ដ.ដ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២0២0 របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ និងដីកាសន្និដ្ឋានស្តាពរលេខ ៤៦៩៤ អ.ឃ.ឃ ចុះថ្ងៃទី0១ ខែធ្នូ

កញ្ញា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានចោទប្រកាន់លើឈ្មោះ [redacted] សៀង ងាន់ ហៅ អាមាន់ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្បែរវិទ្យាល័យជាស៊ីម ប៊ឹង កេងកង សង្កាត់ប៊ឹងកេងកង ខណ្ឌប៊ឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០២០ តាមបញ្ញត្តិ មាត្រា ៤០ កថាខណ្ឌ៣ ចំណុច១១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២/. នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] សៀងងាន់ បានឆ្លើយថា៖ កាលពីថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០២០ ខ្លួនពិតជាបានយក ថ្នាំញៀនចំនួន០១កញ្ចប់ធំ (ប្រភេទ K និងប្រភេទ LV មិនដឹងពីចំនួន) ដែលឈ្មោះ ផល ប្រាប់ថាអោយខ្លួនយកទៅអោយ ឈ្មោះ វុធ ហៅ ឌីជេវុធ នៅម្តុំវិទ្យាល័យជាស៊ីមប៊ឹងកេងកង ពេលទៅ ដល់ក្រោយវិទ្យាល័យខ្លួនបានទូរស័ព្ទរកឈ្មោះ វុធ អោយមកយកថ្នាំញៀន ពេលឈ្មោះ វុធ មកដល់ក៏ត្រូវ សមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

៣/. តាមអង្គហេតុ ចម្លើយសារភាពរបស់ជនជាប់ចោទ និងរបាយការណ៍របស់សមត្ថកិច្ច មានភាពស៊ី សង្វាក់គ្នាអាចបង្ហាញអោយឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើទុច្ចរិត ជួញដូរដោយខុសច្បាប់នូវសារ ធាតុញៀន តាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៣ ចំណុច១១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ពិតប្រាកដ មែន ។

៤/. អំពើ និងសកម្មភាពរបស់ជនជាប់ចោទ ធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ជាពិសេសប៉ះពាល់ដល់សុខភាពអ្នកដទៃធ្ងន់ធ្ងរ និងប៉ះពាល់ដល់សីលធម៌ប្រសាទ អំពើនេះគឺជាអំពើល្មើសដែលមាន ចែងក្នុងមាត្រា ៤០ កថាខណ្ឌ៣ ចំណុច១១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៥/. ពេលធ្វើសកម្មភាពជនជាប់ចោទមានស្មារតី និងសមត្ថភាពគ្រប់គ្រាន់ ប្រព្រឹត្តអំពើល្មើសច្បាប់រហូត សម្រេចបំណងរបស់ខ្លួន ហើយជានីតិជន ដែលមានសមត្ថភាពពេញលេញក្នុងការទទួលខុសត្រូវនូវអំពើរបស់ ខ្លួនដែលបានប្រព្រឹត្ត ។

៦/. តាមលទ្ធផលកោសល្យវិច្ច័យគ្រឿងញៀនលេខ ២៦១៣០/២០ ម.ព.អ.ជ.ប.ក.ញ ចុះថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋានមន្ទីរពិសោធន៍គ្រឿងញៀន ជាលទ្ធផលបញ្ជាក់ថា៖

ក/សំណាកទី១៖ ជាគ្រឿងញៀនប្រភេទគ្រាប់ ឈ្មោះ **អឹម ដេ អឹម អា** (ហៅក្រៅ អ៊ិចស្តាស៊ី) ,ដែលមាន កម្រិតភាព សុទ្ធ ៥៦,៥០% នៃទម្ងន់សរុប វាស្ថិតក្នុងតារាងទី១ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែង លម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

ខ/សំណាកទី២៖ ជាគ្រឿងញៀនប្រភេទក្រាមម្សៅ ឈ្មោះ កេតាមីន ,ដែលមានកម្រិតភាពសុទ្ធ ៦២,០៣% នៃទម្ងន់សរុប ។

គ/សំណាកទី៣៖ ជាគ្រឿងញៀនប្រភេទគ្រាប់ ឈ្មោះ **ឌីមេតាហ្សេប៉ាម** ,ដែលមានកម្រិតភាពសុទ្ធ ៣% នៃទម្ងន់សរុប វាស្ថិតក្នុងតារាងទី៣ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

៧/. តាមការគណនាអំពីភាពសុទ្ធនៃគ្រឿងញៀនប្រភេទគ្រាប់ឈ្មោះ **អឹម ដេ អឹម អា** របស់ជនជាប់ចោទឈ្មោះ [redacted] **សៀងងាន់** មានទម្ងន់សរុប ៦៧,១៧ (ហុកសិបប្រាំពីរក្បៀសដប់ប្រាំពីរ) ក្រាម ដែល (៦៧,១៧ ក្រាម x ៥៦,៥0%) ចែកនឹង១00 ឃើញថាបរិមាណនៃភាពសុទ្ធមានចំនួន ៣៧,៩៥ (សាមសិបប្រាំពីរក្បៀសកៅសិបប្រាំ) ក្រាម ។

លទ្ធផល ៣៧,៩៥ក្រាម គឺស្ថិតក្នុងតារាងទី១ មាត្រា ៤0 កថាខណ្ឌ៣ ចំណុច១១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៨/. តាមការគណនាអំពីភាពសុទ្ធនៃគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ **កេតាមីន** របស់ជនជាប់ចោទឈ្មោះ **ឆាយ សៀងងាន់** មានទម្ងន់សរុប ៦២,0៣ (ហុកសិបពីរក្បៀសសូន្យបីមួយ) ក្រាម ដែល (៥៦,៣៧ក្រាម x ២៦,0៣%) ចែកនឹង១00 ឃើញថាបរិមាណនៃភាពសុទ្ធមានចំនួន ៣៥,១៨ (សាមសិបប្រាំពីរក្បៀសកៅសិបប្រាំ) ក្រាម ។

លទ្ធផល ៣៥,១៨ក្រាម គឺស្ថិតក្នុងតារាងទី៣ មាត្រា ៤0 កថាខណ្ឌ៣ ចំណុច១១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៩/. តាមការគណនាអំពីភាពសុទ្ធនៃគ្រឿងញៀនប្រភេទគ្រាប់ ឈ្មោះ **នីមេតាហ្សេប៉ាម** របស់ជនជាប់ចោទឈ្មោះ [redacted] **សៀងងាន់** មានទម្ងន់សរុប ១,២៦ (មួយក្បៀសម្ភៃប្រាំមួយ) ក្រាម ដែល (១,២៦ក្រាម x ៣%) ចែកនឹង ១00 ឃើញថាបរិមាណនៃភាពសុទ្ធមានចំនួន 0,0៣ (សូន្យក្បៀសសូន្យបី) ក្រាម ។

លទ្ធផល 0,0៣ក្រាម គឺស្ថិតក្នុងតារាងទី៣ មាត្រា ៤0 កថាខណ្ឌ៣ ចំណុច១១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១0/. គ្រឿងញៀនដែលបានដកហូតពីជនជាប់ចោទ គឺជាគ្រឿងញៀនដែលបានធ្វើសកម្មភាពជួញដូរដូច្នេះគប្បីតុលាការពិចារណាសម្រេចផ្តន្ទាទោសលើជនជាប់ចោទឱ្យទទួលទោសពន្ធនាគារ ដោយផ្អែកលើសារធាតុសុទ្ធនៃគ្រឿងញៀននេះ ។

១១/. តំណាងអយ្យការបានសន្និដ្ឋានថា: សុំរក្សាការចោទប្រកាន់ទុកនៅដដែល គប្បីតុលាការលើកមកពិចារណា ។

១២/. មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានសន្និដ្ឋានថា សុំតុលាការបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង គប្បីតុលាការលើកមកពិចារណា ។

១៣/. ជនជាប់ចោទឈ្មោះ ផល អាទប្រុស អាយុប្រហែល៣៧ឆ្នាំ គ្មានអត្តសញ្ញាណជាតិគ្រប់គ្រាន់ ត្រូវបានចៅក្រម សើបសួរចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់លេខ ៦១៣៨ (៣).ដដ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២0២0 រួចហើយ។

១៤/. មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **សៀងងាន់** ហៅ **អាមាន់** អាទប្រុស អាយុ២៩ឆ្នាំ ជនជាតិខ្មែរ ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្បែរវិទ្យាល័យជាស៊ីម បឹងកេងកង

សង្កាត់បឹងកេងកង ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ ចំណុច១១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៥/. វត្ថុចាប់យកដែលមាននៅក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ១៦៧០ រ.វ.ត ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ មានដូចជា៖

ក/. ស្រោមសំបុត្រពណ៌គគីបិទជិតមានសរសេរថា៖ មានចំនួន០៣ប្រភេទ ១ថ្នាំគ្រាប់ពណ៌ចំរុះ ទម្ងន់ ៦៧,១៧ក្រាម (ហុកសិបប្រាំពីរ កណ្តាក់សញ្ញា ដប់ប្រាំពីរក្រាម) (MDMA) ២,ក្រាមពណ៌សថ្នា ទម្ងន់ ៥៦,៧៣ ក្រាម (ហាសិបប្រាំមួយកណ្តាក់សញ្ញាចិតសិបបី) ក្រាម (កេតាមីន) ៣,ថ្នាំគ្រាប់ឌីមេតាហ្សេប៉ាម ទម្ងន់ ១,២៦ក្រាម (មួយកណ្តាក់សញ្ញា ម្ភៃប្រាំមួយ) ក្រាម ដោយមានស្នាមផ្តិតមេដៃរបស់ជនជាប់ចោទឈ្មោះ ឆាយ សៀងដាន់ និង មានចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ។

វត្ថុចាប់យកនេះ ជាមធ្យោបាយប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចរឹបអូស តាមមាត្រា ៩៣ និង មាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ខ/. រថយន្តម៉ាក ប្រ៊ូស ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 2AP-5932 ចំនួន០១គ្រឿង ជារបស់តតិយជន ឈ្មោះ [redacted] **ឈឺនស្រ៊ាន** អាទស្រី គប្បីសម្រេចប្រគល់អោយម្ចាស់ដើមវិញ ។

ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោស

ឈ្មោះ [redacted] **សៀងដាន់** ហៅ **អាអាន់** អាទប្រុស អាយុ២៩ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ចំនួន ០៥ (ប្រាំ) **ឆ្នាំ** និងពិន័យជាប្រាក់កំណត់ចំនួន **១០,០០០.០០០រ** (**ដប់លាន**)**រៀល** ។

ពីបទ៖ **ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចក្បែរវិទ្យាល័យជាស៊ីម បឹងកេងកង សង្កាត់បឹងកេងកង ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០២០ តាម បញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ ចំណុច១១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-រឹបអូសវត្ថុចាប់យក ដែលមាននៅក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ១៦៧០ រ.វ.ត ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០២០ រួមមាន៖

ក/. ស្រោមសំបុត្រពណ៌គគីបិទជិតមានសរសេរថា៖ មានចំនួន០៣ប្រភេទ ១,ថ្នាំគ្រាប់ពណ៌ចំរុះ ទម្ងន់ ៦៧,១៧ក្រាម (ហុកសិបប្រាំពីរ កណ្តាក់សញ្ញា ដប់ប្រាំពីរក្រាម) (MDMA) ២,ក្រាមពណ៌សថ្នា ទម្ងន់ ៥៦,៧៣ ក្រាម (ហាសិបប្រាំមួយកណ្តាក់សញ្ញា ចិតសិបបី) ក្រាម (កេតាមីន) ៣,ថ្នាំគ្រាប់ឌីមេតាហ្សេប៉ាម ទម្ងន់ ១,២៦ ក្រាម (មួយ កណ្តាក់សញ្ញា ម្ភៃប្រាំមួយ) ក្រាម ត្រូវរឹបអូសបំផ្លាញចោលមាត្រា៩៣ និងមាត្រា៩៤ នៃច្បាប់ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន ។

ខ/. រថយន្តម៉ាក ប្រ៊ូស ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 2AP-5932 ចំនួន០១គ្រឿង ត្រូវប្រគល់អោយ ម្ចាស់ដើមវិញ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅ
ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សៀងងាន់ ។
ភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

ក្រឡាបញ្ជីសវនាការ	ចៅក្រមប្រឹក្សា	ចៅក្រមប្រឹក្សា	ប្រធានក្រុមប្រឹក្សា
ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា
[redacted]			

(បានចម្លងត្រឹមត្រូវតាមច្បាប់ដើម)

បានឃើញ

ប្រធានក្រុមប្រឹក្សា

[redacted]

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

Scanned with CamScanner